ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ...១៩៤/២៣...ក.ប/ប្រ.ក.ប.ស.ស

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់វិភាជន៍មរណភាព ក្នុងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)
- បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន
- បានឃើញប្រកាសលេខ២៣៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីតាវកាលិកហានិភ័យការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះកំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់វិភាជន៍បូជាសពក្នុងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារដើម្បីធានាឱ្យមានសង្គតិភាព និងធ្វើឱ្យប្រសើរឡើងនៃតាវកាលិករបបសន្តិសុខសង្គមផ្នែកហានិភ័យការងារស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះបុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដូចមានចែងក្នុងមាត្រា៣ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។

**ប្រការ៣ .-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗ ដែលប្រើក្នុងប្រកាសនេះមានកំណត់និយមន័យដូចខាងក្រោម៖

- *សិទ្ធិវន្តនៃវិភាជន៍បូជាសព* សំដៅដល់បុគ្គលដែលមានសិទ្ធិទទួលបានវិភាជន៍បូជាសពជាអាទិ៍សាច់ញាតិរបស់ជនរងគ្រោះ ឬអ្នកដែលចាត់ចែងបូជាសពជនរងគ្រោះដែលបណ្តាលមកពីហានិភ័យការងារ។
- *វិភាជន៍បូជាសព* សំដៅដល់ប្រាក់ឧបត្ថម្ភសម្រាប់ការចាត់ចែងបូជាសពសមាជិក **ប.ស.ស**. ដែលទទួលរងហានិភ័យការងាររហូតដល់បាត់បង់ជីវិត។

## ជំពូកទី២
## លក្ខខណ្ឌនៃការផ្តល់វិភាជន៍បូជាសព

**ប្រការ៤ .-**

សិទ្ធិវន្តនៃសមាជិក **ប.ស.ស**. មានសិទ្ធិទទួលបានវិភាជន៍បូជាសពក្នុងករណីដែលសមាជិក **ប.ស.ស**. ទទួលរងគ្រោះដោយហានិភ័យការងាររហូតដល់បាត់បង់ជីវិត។

វិភាជន៍បូជាសពផ្នែកហានិភ័យការងារ ត្រូវកំណត់ស្មើនឹង ១០ ០០០ ០០០ (ដប់លាន)រៀល។

## ជំពូកទី៣
## បែបបទ និងនីតិវិធីនៃការផ្តល់វិភាជន៍បូជាសព

**ប្រការ៥ .-**

សិទ្ធិវន្តនៃវិភាជន៍បូជាសព ត្រូវបំពេញទម្រង់ទាមទារ "**តាវកាលិកផ្នែកហានិភ័យការងារ**" ដោយត្រូវភ្ជាប់ជាមួយនូវសេចក្តីចម្លងសំបុត្រមរណភាព ឬឯកសារផ្សេងៗដែលកំណត់ដោយ **ប.ស.ស**.។

ទម្រង់នៃការទាមទារ "**តាវកាលិកផ្នែកហានិភ័យការងារ**" ត្រូវកំណត់ដោយអគ្គនាយក **ប.ស.ស**.។

**ប្រការ៦ .-**

សិទ្ធិវន្តនៃវិភាជន៍បូជាសព ត្រូវបំពេញទម្រង់ទាមទារវិភាជន៍បូជាសពក្នុងកំឡុងពេល ៣(បី)ខែ បន្ទាប់ពីការទទួលមរណភាពរបស់សមាជិក **ប.ស.ស**.។

សិទ្ធិនៃការទាមទារវិភាជន៍បូជាសពក្នុងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារត្រូវអស់សុពលភាពត្រឹមរយៈពេល ១(មួយ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលមរណភាពរបស់សមាជិក **ប.ស.ស**.។



Ala.

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**ប្រការ៧ .-**

សមាជិក **ប.ស.ស**. ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលរងគ្រោះដោយហានិភ័យការងាររហូតដល់បាត់បង់ជីវិតមុនប្រកាសនេះចូលជាធរមាន ត្រូវអនុវត្តតាមប្រកាសលេខ២៣៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១០រោច ខែ បឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៩
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ